ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធ នឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្របដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តន៍ប្រកបដោយសង្គតិភាព ។

(ខ) គោរពតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធ នឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើមានការខុសប្លែកពីនេះ ដើម្បីបង្ហាញភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញ និងពន្យល់ឲ្យបានច្បាស់លាស់ និងកំណត់ បរិមាណនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព ។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្មទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្មនិងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យលើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការធនាគារឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

(ង) ត្រួតពិនិត្យ និងដឹកនាំសម្ព័ន្ធធនាគារ និងធនាគារឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេច ដែលមានសារៈសំខាន់ទាំងអស់ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់សម្ព័ន្ធធនាគារ និងធនាគារហើយត្រូវប្រាកដថា កិច្ចការនេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុង
របាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តរាល់តម្រូវការដូចបានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ។

# ធនាគារភ្នំពេញពាណិជ្ជ

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំសូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញនៅទំព័រទី10 ដល់ទី 104ដែលតាមមតិរបស់យើងខ្ញុំគឺបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

*ចុះហត្ថលេខាដោយយោងទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល:*

លោក Shin Chang Moo
*អគ្គនាយកប្រតិបត្តិ*

រាជធានីភ្នំពេញព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី28 ខែ កុម្ភៈ ឆ្នាំ 2017

# របាយការណ៍របស់សវនករឯករាជ្យ
## ជូនចំពោះម្ចាស់ភាគហ៊ុន
## ធនាគារភ្នំពេញពាណិជ្ជ

### មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ **ធនាគារភ្នំពេញពាណិជ្ជ និងបុត្រសម្ព័ន្ធ**ហៅកាត់ថា (“សម្ព័ន្ធធនាគារ”) និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ **ធនាគារភ្នំពេញពាណិជ្ជ** ហៅកាត់ថា (“ធនាគារ”) ដែលរួមមានតារាងតុល្យការរួម និងដោយឡែកនៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016និង របាយការណ៍លទ្ធផលរួម និងដោយឡែក របាយការណ៍បម្រែបម្រួល
មូលធន និងលំហូរទឹកប្រាក់រួម និងដោយឡែករបស់សម្ព័ន្ធធនាគារ និងធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សំគាល់ដែលរួមមាន សេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗដែលបានបង្ហាញនៅទំព័រទី 10 ដល់ទី 104 (ហៅកាត់ថា “របាយការណ៍ហិរញ្ញវត្ថុ”)។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់សម្ព័ន្ធធនាគារ និងធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

### មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុង កថាខ័ណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននូវក្នុងរបាយការណ៍របស់យើងខ្ញុំ ។ យើងខ្ញុំ មានភាពឯករាជ្យពីសម្ព័ន្ធធនាគារ និងធនាគារដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើក្រមសីលធម៌វិជ្ជាជីវៈស្របតាមតម្រូវការរបស់ស្តង់ដារទាំងនោះ ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជា
មូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

## ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងនិងអ្នកទទួលខុសត្រូវលើអភិបាលកិច្ចនៃបាយការណ៍ហិរញ្ញវត្ថុ

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ នេះដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហា ទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការសម្ព័ន្ធធនាគារ និងធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ចមានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំគឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយប៉ុន្តែវាមិនអាចធានាថាគ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាអាចរកឃើញនូវកាបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ ។ កាបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏ៈ

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចរួមបញ្ចូលទាំងការឃុបឃិតគ្នាការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។

- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់សម្ព័ន្ធធនាគារ និងធនាគារឡើយ ។
- ការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលសម្ព័ន្ធធនាគារ និងធនាគារបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង ។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រងហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់សារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារ ដើម្បីបន្តនិរន្តរភាពអាជីវកម្ម ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ។ យ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឲ្យសម្ព័ន្ធធនាគារ និងធនាគារបញ្ឈប់និរន្តរភាពនៃអាជីវកម្ម ។
- វាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំ ផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ស្តីពីបញ្ហាផ្សេងទៀត វិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានរួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា ចំកាត់**




**ខៃ ហ៊ុយ**

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 28 ខែ កុម្ភៈ ឆ្នាំ 2017

## ធនាគារភ្នំពេញពាណិជ្ជ

## តារាងតុល្យការរួម
## នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

| | កំណត់សំគាល់ | 2016 ដុល្លារអាមេរិក | 2016 ពាន់រៀល (កំណត់សំគាល់ 4) | 2015 ដុល្លារអាមេរិក | 2015 ពាន់រៀល (កំណត់សំគាល់ 4) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់និងសមតុល្យធនាគារ | 5 | 29,524,517 | 119,190,475 | 62,487,036 | 253,072,496 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារ និងស្ថាប័នហិរញ្ញវត្ថុនានា | 6 | 76,915,000 | 310,505,855 | 68,138,750 | 275,961,938 |
| ឥណទាន និងបុរេប្រទាន - សុទ្ធ | 7 | 308,492,754 | 1,245,385,248 | 226,122,681 | 915,796,858 |
| ទ្រព្យសកម្មផ្សេងៗ | 8 | 4,196,834 | 16,942,619 | 3,946,291 | 15,982,477 |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | 9 | 45,208,000 | 182,504,696 | 38,406,000 | 155,544,300 |
| ទ្រព្យសកម្មអរូបី | 10 | 1,066,079 | 4,303,761 | 413,692 | 1,675,453 |
| ទ្រព្យ និងបរិក្ខារ | 11 | 14,484,689 | 58,474,689 | 14,582,950 | 59,060,948 |
| ពន្ធពន្យារជាទ្រព្យសកម្ម | 14 | 597,325 | 2,411,401 | - | - |
| **សរុបទ្រព្យសកម្ម** | | 480,485,198 | 1,939,718,744 | 414,097,400 | 1,677,094,470 |
| **បំណុល និងមូលនិធិម្ចាស់ភាគហ៊ុន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 12 | 317,507,103 | 1,281,776,175 | 276,040,143 | 1,117,962,579 |
| ប្រាក់បញ្ញើរបស់ធនាគារនានា | 13 | 74,933,739 | 302,507,504 | 75,319,324 | 305,043,262 |
| ពន្ធលើប្រាក់ចំណេញត្រូវបង់ | 14 | 934,941 | 3,774,357 | 779,236 | 3,155,906 |
| បំណុលផ្សេងៗ | 15 | 9,344,003 | 37,721,740 | 6,728,115 | 27,248,866 |
| **សរុបបំណុល** | | 402,719,786 | 1,625,779,776 | 358,866,818 | 1,453,410,613 |
| **មូលនិធិម្ចាស់ភាគហ៊ុន** | | | | | |
| ដើមទុន | 17 | 59,000,000 | 238,183,000 | 39,000,000 | 157,950,000 |
| ទុនបម្រុងផ្សេងៗ | 18 | 5,000,000 | 20,185,000 | - | - |
| ប្រាក់ចំណេញរក្សាទុក | | 13,765,412 | 55,570,968 | 16,230,582 | 65,733,857 |
| **សរុបមូលនិធិម្ចាស់ភាគហ៊ុន** | | 77,765,412 | 313,938,968 | 55,230,582 | 223,683,857 |
| **សរុបបំណុល និងមូលនិធិម្ចាស់ភាគហ៊ុន** | | 480,485,198 | 1,939,718,744 | 414,097,400 | 1,677,094,470 |

-

កំណត់សំគាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

## របាយការណ៍លទ្ធផលរួម
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2016

| | កំណត់សំគាល់ | 2016 ដុល្លារអាមេរិក | 2016 ពាន់រៀល (កំណត់សំគាល់ 4) | 2015 ដុល្លារអាមេរិក | 2015 ពាន់រៀល (កំណត់សំគាល់ 4) |
|---|---|---|---|---|---|
| ចំណូលពីការប្រាក់ | 19 | 28,561,359 | 115,302,206 | 22,918,887 | 92,821,493 |
| ចំណាយលើការប្រាក់ | 20 | (14,630,417) | (59,062,993) | (11,221,279) | (45,446,180) |
| **ចំណូលពីការប្រាក់សុទ្ធ** | | 13,930,942 | 56,239,213 | 11,697,608 | 47,375,313 |
| ចំណូលពីថ្លៃឈ្នួល និងកម្រៃជើងសា | 21 | 4,146,494 | 16,739,396 | 3,639,418 | 14,739,644 |
| ចំណាយលើថ្លៃឈ្នួល និងកម្រៃជើងសា | | (325,105) | (1,312,449) | (57,952) | (234,706) |
| **ចំណូលសុទ្ធពីថ្លៃឈ្នួល និងកម្រៃជើងសារ** | | 3,821,389 | 15,426,947 | 3,581,466 | 14,504,938 |
| ចំណូលផ្សេងៗ | 22 | 306,790 | 1,238,511 | 88,609 | 358,866 |
| **សរុបចំណេញសុទ្ធពីប្រតិបត្តិការ** | | 18,059,121 | 72,904,671 | 15,367,683 | 62,239,117 |
| ចំណាយទូទៅ និងរដ្ឋបាល | 23 | (13,155,044) | (53,106,913) | (10,368,109) | (41,990,842) |
| សំវិធានធនឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ | 7 | (1,345,249) | (5,430,770) | (584,085) | (2,365,544) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | 3,558,828 | 14,366,988 | 4,415,489 | 17,882,731 |
| ពន្ធលើប្រាក់ចំណេញ | 14 | (1,104,117) | (4,457,320) | (1,020,688) | (4,133,786) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | 2,454,711 | 9,909,668 | 3,394,801 | 13,748,945 |

កំណត់សំគាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

## របាយការណ៍បម្រែបម្រួលមូលធនរួម
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

| | ដើមទុន ដុល្លារអាមេរិក | ទុនបម្រុងផ្សេងៗ ដុល្លារអាមេរិក | ប្រាក់ចំណេញរក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|
| សមតុល្យនាថ្ងៃទី1 ខែមករា ឆ្នាំ 2015 | 39,000,000 | - | 12,835,781 | 51,835,781 |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 3,394,801 | 3,394,801 |
| សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2015 | 39,000,000 | - | 16,230,582 | 55,230,582 |
| (ស្មើនឹងពាន់រៀល - កំណត់សំគាល់ 4) | 157,950,000 | - | 65,733,857 | 223,683,857 |
| សមតុល្យនាថ្ងៃទី1 ខែមករា ឆ្នាំ 2016 | 39,000,000 | - | 16,310,701 | 55,310,701 |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 2,454,711 | 2,454,711 |
| ការបង្កើនដើមទុន | 20,000,000 | - | - | 20,000,000 |
| ការផ្ទេរ | - | 5,000,000 | (5,000,000) | - |
| សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 | 59,000,000 | 5,000,000 | 13,765,412 | 77,765,412 |
| (ស្មើនឹងពាន់រៀល - កំណត់សំគាល់ 4) | 238,183,000 | 20,185,000 | 55,570,968 | 313,938,968 |

កំណត់សំគាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

## របាយការណ៍លំហូរទឹកប្រាក់រួម
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

| | កំណត់សំគាល់ | 2016 ដុល្លារអាមេរិក | 2016 ពាន់រៀល (កំណត់សំគាល់ 4) | 2015 ដុល្លារអាមេរិក | 2015 ពាន់រៀល (កំណត់សំគាល់ 4) |
|---|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/បានពីសកម្មភាពប្រតិបត្តិការ | 24 | (43,195,669) | (174,380,917) | 28,307,333 | 114,644,699 |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញ: | | | | | |
| ទ្រព្យ និងបរិក្ខារ | | (1,631,529) | (6,586,483) | (6,197,628) | (25,100,393) |
| ទ្រព្យសកម្មអរូបី | | (229,321) | (925,769) | (2,796) | (11,324) |
| ចំណូលពីការលក់ទ្រព្យ និងបរិក្ខារ | | 94,000 | 379,478 | - | - |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | (1,766,850) | (7,132,774) | (6,200,424) | (25,111,717) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ទឹកប្រាក់ទទួលបានពីការបង្កើនដើមទុន | | 20,000,000 | 80,740,000 | - | - |
| **ទឹកប្រាក់ទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | | 20,000,000 | 80,740,000 | - | - |
| **ការ(ថយចុះ)/កើនឡើងសុទ្ធនៃសាច់ប្រាក់និងសាច់ប្រាក់សមមូល** | | (24,962,519) | (100,773,691) | 22,106,909 | 89,532,982 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី 1 ខែ មករា** | | 64,887,036 | 262,792,496 | 42,780,127 | 174,329,018 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (843,530) | - | (1,069,504) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី 31 ខែ ធ្នូ** | 25 | 39,924,517 | 161,175,275 | 64,887,036 | 262,792,496 |

# របាយការណ៍លំហូរទឹកប្រាក់រួម (ត)
# សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## ប្រតិបត្តិការមិនមែនជាសាច់ប្រាក់សំខាន់ៗ

ក្នុងការិយបរិច្ឆេទ មានប្រតិបត្តិការមិនមែនសាច់ប្រាក់សំខាន់ៗទាក់ទងនឹងទ្រព្យសកម្មបំណុល និងចំណេញរក្សាទុកពីការរួមបញ្ចូលអាជីវកម្មតាមរយៈការគ្រប់គ្រងរួម ដូចខាងក្រោម៖

| | សម្រាប់ការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2016 | |
|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) |
| *ទទួលស្គាល់ជាទ្រព្យសកម្ម បំណុល និងចំណេញរក្សាទុករបស់បុត្រសម្ព័ន្ធ ** | | |
| ទ្រព្យ និងបរិក្ខារ | 593,996 | 2,397,962 |
| ទ្រព្យសកម្មផ្សេងៗ | 1,312 | 5,297 |
| បំណុលផ្សេងៗ | (1,465) | (5,914) |
| ប្រាក់ចំណេញរក្សាទុក | (80,119) | (323,440) |

* ការទទួលស្គាល់ជាទ្រព្យសកម្ម បំណុល និងចំណេញរក្សាទុករបស់បុត្រសម្ព័ន្ធខាងលើ មិនបានរួមបញ្ចូលការលុបចោលរវាងប្រតិបត្តិការ និងសមតុល្យក្នុងអន្តរសម្ព័ន្ធធនាគារ និងលទ្ធផលនៃប្រាក់ចំណេញមិនជាក់លាក់ ។

កំណត់សំគាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ

# ធនាគារភ្នំពេញពាណិជ្ជ

## តារាងតុល្យការដោយឡែក
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ2016

| | កំណត់សំគាល់ | 2016 ដុល្លារអាមេរិក | 2016 ពាន់រៀល (កំណត់សំគាល់ 4) | 2015 ដុល្លារអាមេរិក | 2015 ពាន់រៀល (កំណត់សំគាល់ 4) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់និងសមតុល្យធនាគារ | 5 | 29,524,517 | 119,190,475 | 62,487,036 | 253,072,496 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារ និងស្ថាប័នហិរញ្ញវត្ថុនានា | 6 | 76,915,000 | 310,505,855 | 68,138,750 | 275,961,938 |
| ឥណទាន និងបុរេប្រទាន - សុទ្ធ | 7 | 308,997,654 | 1,247,423,529 | 226,122,681 | 915,796,858 |
| ទ្រព្យសកម្មផ្សេងៗ | 8 | 4,688,780 | 18,928,605 | 3,946,291 | 15,982,477 |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | 9 | 45,208,000 | 182,504,696 | 38,406,000 | 155,544,300 |
| ទ្រព្យសកម្មអរូបី | 10 | 1,066,079 | 4,303,761 | 413,692 | 1,675,453 |
| ទ្រព្យ និងបរិក្ខារ | 11 | 13,716,967 | 55,375,396 | 14,582,950 | 59,060,948 |
| ពន្ធពន្យារជាទ្រព្យសកម្ម | 14 | 597,325 | 2,411,401 | - | - |
| **សរុបទ្រព្យសកម្ម** | | 480,714,322 | 1,940,643,718 | 414,097,400 | 1,677,094,470 |
| **បំណុល និងមូលនិធិម្ចាស់ភាគហ៊ុន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 12 | 317,951,966 | 1,283,572,087 | 276,040,143 | 1,117,962,579 |
| ប្រាក់បញ្ញើរបស់ធនាគារនានា | 13 | 74,933,739 | 302,507,504 | 75,319,324 | 305,043,262 |
| ពន្ធលើប្រាក់ចំណេញត្រូវបង់ | 14 | 904,145 | 3,650,033 | 779,236 | 3,155,906 |
| បំណុលផ្សេងៗ | 15 | 9,338,660 | 37,700,170 | 6,728,115 | 27,248,866 |
| **សរុបបំណុល** | | 403,128,510 | 1,627,429,794 | 358,866,818 | 1,453,410,613 |
| **មូលនិធិម្ចាស់ភាគហ៊ុន** | | | | | |
| ដើមទុន | 17 | 59,000,000 | 238,183,000 | 39,000,000 | 157,950,000 |
| ទុនបម្រុងផ្សេងៗ | 18 | 5,000,000 | 20,185,000 | - | - |
| ប្រាក់ចំណេញរក្សាទុក | | 13,585,812 | 54,845,924 | 16,230,582 | 65,733,857 |
| **សរុបមូលនិធិម្ចាស់ភាគហ៊ុន** | | 77,585,812 | 313,213,924 | 55,230,582 | 223,683,857 |
| **សរុបបំណុល និងមូលនិធិម្ចាស់ភាគហ៊ុន** | | 480,714,322 | 1,940,643,718 | 414,097,400 | 1,677,094,470 |

កំណត់សំគាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

## របាយការណ៍លទ្ធផលដោយឡែក
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016

| | កំណត់សំគាល់ | 2016 ដុល្លារអាមេរិក | 2016 ពាន់រៀល (កំណត់សំគាល់ 4) | 2015 ដុល្លារអាមេរិក | 2015 ពាន់រៀល (កំណត់សំគាល់ 4) |
|---|---|---|---|---|---|
| ចំណូលពីការប្រាក់ | 19 | 28,574,284 | 115,354,385 | 22,918,887 | 92,821,493 |
| ចំណាយលើការប្រាក់ | 20 | (14,630,417) | (59,062,993) | (11,221,279) | (45,446,180) |
| **ចំណូលពីការប្រាក់សុទ្ធ** | | 13,943,867 | 56,291,392 | 11,697,608 | 47,375,313 |
| ចំណូលពីថ្លៃឈ្នួល និងកម្រៃជើងសា | 21 | 4,144,739 | 16,732,311 | 3,639,418 | 14,739,644 |
| ចំណាយលើថ្លៃឈ្នួល និងកម្រៃជើងសា | | (325,105) | (1,312,449) | (57,952) | (234,706) |
| **ចំណូលសុទ្ធពីថ្លៃឈ្នួល និងកម្រៃជើងសារ** | | 3,819,634 | 15,419,862 | 3,581,466 | 14,504,938 |
| ចំណូលផ្សេងៗ | 22 | 306,790 | 1,238,511 | 88,609 | 358,866 |
| **សរុបចំណេញសុទ្ធពីប្រតិបត្តិការ** | | 18,070,291 | 72,949,765 | 15,367,683 | 62,239,117 |
| ចំណាយទូទៅ និងរដ្ឋបាល | 23 | (13,303,638) | (53,706,788) | (10,368,109) | (41,990,842) |
| សំវិធានធនឥណទាន និង បុរេប្រទានអាក្រក់ និងជាប់សង្ស័យ | 7 | (1,350,349) | (5,451,359) | (584,085) | (2,365,544) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | 3,416,304 | 13,791,618 | 4,415,489 | 17,882,731 |
| ពន្ធលើប្រាក់ចំណេញ | 14 | (1,061,074) | (4,283,556) | (1,020,688) | (4,133,786) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | 2,355,230 | 9,508,062 | 3,394,801 | 13,748,945 |

កំណត់សំគាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

# ធនាគារភ្នំពេញពាណិជ្ជ

## របាយការណ៍បម្រែបម្រួលមូលធនដោយឡែក
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ2016

| | ដើមទុន<br>ដុល្លារអាមេរិក | ទុនបម្រុង<br>ផ្សេងៗ<br>ដុល្លារអាមេរិក | ប្រាក់ចំណេញ<br>រក្សាទុក<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|
| សមតុល្យនាថ្ងៃទី1 ខែមករា ឆ្នាំ 2015 | 39,000,000 | - | 12,835,781 | 51,835,781 |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 3,394,801 | 3,394,801 |
| សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2015 | 39,000,000 | - | 16,230,582 | 55,230,582 |
| (ស្មើនឹងពាន់រៀល - កំណត់សំគាល់ 4) | 157,950,000 | - | 65,733,857 | 223,683,857 |
| សមតុល្យនាថ្ងៃទី1 ខែមករា ឆ្នាំ 2016 | 39,000,000 | - | 16,230,582 | 55,230,582 |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 2,355,230 | 2,355,230 |
| ការបង្កើនដើមទុន | 20,000,000 | - | - | 20,000,000 |
| ការផ្ទេរ | - | 5,000,000 | (5,000,000) | - |
| សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 | 59,000,000 | 5,000,000 | 13,585,812 | 77,585,812 |
| (ស្មើនឹងពាន់រៀល - កំណត់សំគាល់ 4) | 238,183,000 | 20,185,000 | 54,845,924 | 313,213,924 |

កំណត់សំគាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

## របាយការណ៍លំហូរទឹកប្រាក់ដោយឡែក
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ2016

| | កំណត់សំគាល់ | 2016 ដុល្លារអាមេរិក | 2016 ពាន់រៀល (កំណត់សំគាល់ 4) | 2015 ដុល្លារអាមេរិក | 2015 ពាន់រៀល (កំណត់សំគាល់ 4) |
|---|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/បានពីសកម្មភាពប្រតិបត្តិការ | 24 | (42,705,669) | (172,402,787) | 28,307,333 | 114,644,699 |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញ: | | | | | |
| ទ្រព្យ និងបរិក្ខារ | | (1,631,529) | (6,586,483) | (6,197,628) | (25,100,393) |
| ទ្រព្យសកម្មអរូបី | | (229,321) | (925,769) | (2,796) | (11,324) |
| ការវិនិយោគផ្សេងៗ | | (490,000) | (1,978,130) | - | - |
| ចំណូលពីការលក់ទ្រព្យ និងបរិក្ខារ | | 94,000 | 379,478 | - | - |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | (2,256,850) | (9,110,904) | (6,200,424) | (25,111,717) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ទឹកប្រាក់ទទួលបានពីការបង្កើនដើមទុន | | 20,000,000 | 80,740,000 | - | - |
| **ទឹកប្រាក់ទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | | 20,000,000 | 80,740,000 | - | - |
| **ការ(ថយចុះ)/កើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | (24,962,519) | (100,773,691) | 22,106,909 | 89,532,982 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី 1 ខែ មករា** | | 64,887,036 | 262,792,496 | 42,780,127 | 174,329,018 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (843,530) | - | (1,069,504) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី 31 ខែ ធ្នូ** | 25 | 39,924,517 | 161,175,275 | 64,887,036 | 262,792,496 |

កំណត់សំគាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ2016

កំណត់សំគាល់ទាំងនេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ហើយគួរតែត្រូវបានអានជាមួយគ្នានឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ជូន ។

### 1. ព័ត៌មានអំពីធនាគារ

**ធនាគារភ្នំពេញពាណិជ្ជ** ហៅកាត់ថា (“ធនាគារ”) ត្រូវបានបង្កើតឡើង និងចុះបញ្ជីជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកំរិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី 20 ខែ ឧសភា ឆ្នាំ 2008 ក្រោមការចុះបញ្ជីពាណិជ្ជកម្មលេខ 00015794 និងបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី 27ខែ សីហា ឆ្នាំ 2008 ។ធនាគារបានចាប់ផ្តើមប្រតិបត្តិការជាផ្លូវការនៅថ្ងៃទី 1 ខែ កញ្ញា ឆ្នាំ 2008 ។

សកម្មភាពចម្បងៗរបស់ធនាគារ គឺផ្តល់សេវាកម្មផ្នែកធនាគារ និងហិរញ្ញវត្ថុដែលពាក់ព័ន្ធផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។នៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 ធនាគារមានទីស្នាក់ការកណ្តាលមួយ និងសាខាចំនួនប្រាំបួនក្នុងក្រុងភ្នំពេញ និងសាខាចំនួនបួននៅខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកំពង់ចាម និងខេត្តព្រះសីហនុ ។

បុត្រសម្ព័ន្ធ Star and Crane Cam Co., Ltd ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត ត្រូវបានបង្កើតឡើង និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី 28 ខែ សីហា ឆ្នាំ 2014 ក្រោមការចុះបញ្ជីពាណិជ្ជកម្មលេខ 00013276 ។
សកម្មភាពចម្បងៗរបស់បុត្រសម្ព័ន្ធគឺជាអ្នកធ្វើប្រតិបត្តិការដោយផ្ទាល់ឬដោយប្រយោលលើអាជីវកម្មណាមួយទាក់ទងនឹងភតិសន្យាស្របច្បាប់និងជាឃ្លាំងស្តុកដាក់ផលិតផលគ្រប់ប្រភេទ។

សម្ព័ន្ធធនាគារ និងធនាគារមានបុគ្គលិកសរុបចំនួន 258នាក់ នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 (ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2015: 221 នាក់) ។

### 2. មូលដ្ឋាននៃការរៀបចំ

#### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងស្របតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។
របាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុម័ត និងផ្តល់សិទ្ធិផ្សាយឲ្យប្រើប្រាស់ដោយក្រុមប្រឹក្សាភិបាលនៅ ថ្ងៃទី28ខែកុម្ភៈ ឆ្នាំ 2017។

#### (ខ) មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើម ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ2016

### 2. មូលដ្ឋាននៃការរៀបចំ ( ត )

#### (គ) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល ។ ដោយសារសម្ព័ន្ធធនាគារ និងធនាគារធ្វើប្រតិបត្តិការ និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក អ្នកគ្រប់គ្រង ក៏បានកំណត់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញព្រោះវាបានឆ្លុះបញ្ចាំងពីភាពចាំបាច់នៃសេដ្ឋកិច្ច ប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់សម្ព័ន្ធធនាគារ និងធនាគារ។

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ ដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។ សមតុល្យនៃទ្រព្យសកម្មរូបិយប័ណ្ណ និងបំណុលរូបិយប័ណ្ណនាកាលបរិច្ឆេទរាយការណ៍ ដែលជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិកក៏ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រានាកាលបរិច្ឆេទនោះ ។ភាពលំអៀងពីការប្តូររូបិយប័ណ្ណដែលកើតមកពីការប្តូរនោះ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់សម្ព័ន្ធធនាគារ និងធនាគារ។ តួរលេខទាំងអស់ត្រូវបានកាត់ខ្ទង់ចំនួនមួយដុល្លារអាមេរិកដែលជិតបំផុត ឬលុះត្រាមានការបង្ហាញផ្សេងពីនោះ ។

#### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតម្រូវឲ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតផលប៉ះពាល់ដល់ការអនុវត្តន៍នូវគោលការណ៍គណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុលចំណូលនិងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ ។

ការប៉ាន់ស្មាន និងការសន្មតត្រូវបានត្រួតពិនិត្យជាប្រចាំ ។ ការកែប្រែទៅលើគណនេយ្យប៉ាន់ស្មាន ត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងការិយបរិច្ឆេទដែលការប៉ាន់ស្មាននោះត្រូវបានកែប្រែ និង ការិយបរិច្ឆេទអនាគតដែលមានផលប៉ះពាល់ដោយការប្រែប្រួលនេះ ។

ការប៉ាន់ស្មាន និងការវិនិច្ឆ័យគណនេយ្យចម្បង ត្រូវបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួមមានការប៉ាន់ស្មាននូវចំនួនដែលអាចប្រមូលបានមកវិញពីឥណទាននិងបុរេប្រទាន ដែលបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែកក្នុងកំណត់សំគាល់ទី 3 (ច) ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗ ដែលបានប្រើប្រាស់ដោយសម្ព័ន្ធធនាគារ និងធនាគារក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះមានដូចខាងក្រោម ។ គោលនយោបាយទាំងនេះ ត្រូវបានប្រើប្រាស់សម្រាប់គ្រប់ការិយបរិច្ឆេទទាំងអស់ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះប្រកបដោយសង្គតិភាព លើកលែងតែចំណុចដែលបានបញ្ជាក់។

### (ក) មូលដ្ឋាននៃការរួមបញ្ចូលគ្នា

#### *(i) ការធ្វើអាជីវកម្មបញ្ចូលគ្នាក្រោមការគ្រប់គ្រងរួម*

របាយការណ៍ហិរញ្ញវត្ថុរួម រួមមានរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងបុត្រសម្ព័ន្ធ ដែលធ្វើឡើងរហូតដល់ចុងការិយបរិច្ឆេទហិរញ្ញវត្ថុ។

ការរួមបញ្ចូលអាជីវកម្ម រវាងក្រុមហ៊ុន ឬអាជីវកម្មដែលស្ថិតនៅក្នុងការគ្រប់គ្រងរួម សំដៅដល់ការរួមបញ្ចូលអាជីវកម្មរបស់ក្រុមហ៊ុន ឬអាជីវកម្ម ដែលទីបំផុតត្រូវគ្រប់គ្រងដោយបុគ្គលតែមួយ ឬភាគីទាំងពីរមុនពេល និងក្រោយពេលរួមបញ្ចូលគ្នា និងមិនមែនជាការគ្រប់គ្រងបណ្តោះអាសន្ន ។

បុត្រសម្ព័ន្ធត្រូវបានរួមបញ្ចូលដោយប្រើមូលដ្ឋានគណនេយ្យតម្លៃលើបញ្ជី។ តាមមូលដ្ឋាន គណនេយ្យតម្លៃលើបញ្ជី ការរួមបញ្ចូលអាជីវកម្មក្រោមការគ្រប់គ្រងរួមគ្នា ត្រូវបានបញ្ចូលក្នុង របាយការណ៍ហិរញ្ញវត្ថុរួមគិតចាប់ពីថ្ងៃបន្សំអាជីវកម្មរហូតដល់ថ្ងៃលក់អាជីវកម្ម។

ទ្រព្យសកម្ម និងបំណុលសរុបរបស់បុត្រសម្ព័ន្ធ ត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ក្រុមហ៊ុនមេ ។ ភាពខុសគ្នារវាងការចំណាយនៃការទិញយក និងបរិមាណដែលទ្រព្យសកម្ម និងបំណុលនៃបុត្រសម្ព័ន្ធត្រូវបានកត់ត្រាទុកគឺត្រូវបានទទួលស្គាល់ជាមូលធនដោយផ្ទាល់ នៅក្នុងការធ្វើអាជីវកម្មបញ្ចូលគ្នាក្រោមរូបភាពជាការគ្រប់គ្រងរួម។

នៅក្នុងខែមករាឆ្នាំ 2016 ភាគទុនិករបស់ធនាគារភ្នំពេញពាណិជ្ជបានទិញយកភាគហ៊ុន 49% នៃភាគហ៊ុនទាំងអស់របស់ Star and Crane Cam Co., Ltdក្នុងតម្លៃ 1 ដុល្លារអាមេរិក។ ឯកសារផ្លូវការត្រូវបានបញ្ចប់នៅថ្ងៃទី 30 ខែមិថុនាឆ្នាំ 2016 ។ ទោះជាយ៉ាងណា របាយការណ៍ហិរញ្ញវត្ថុរួម សម្រាប់សម្ព័ន្ធធនាគារនេះ ត្រូវបានរៀបចំឡើង ហាក់ដូចជាសម្ព័ន្ធធនាគារួមនេះបានចាប់ផ្តើមតាំងពីថ្ងៃទី 1 ខែមករា ឆ្នាំ 2016។ បើទោះបីជាសម្ព័ន្ធធនាគារបានគ្រប់គ្រងភាគហ៊ុន 49% នៅក្នុង Star and Crane Cam Co., Ltd ក៏ដោយ ក៏ក្រុមប្រឹក្សាភិបាលជឿជាក់ថា ពួកគេមានការគ្រប់គ្រងលើក្រុមហ៊ុននេះ ដោយសារតែការសម្រេចចិត្តលើហិរញ្ញវត្ថុ និងប្រតិបត្តិការទាំងអស់ត្រូវបានគ្រប់គ្រងដោយសម្ព័ន្ធធនាគារ។

## 3. **គោលនយោបាយគណនេយ្យសំខាន់ៗ** (ត)

### (ក) មូលដ្ឋាននៃការរួមបញ្ចូលគ្នា (ត)

*(ii) បុត្រសម្ព័ន្ធ*

បុត្រសម្ព័ន្ធ គឺជាអង្គភាពដែលគ្រប់គ្រងដោយសម្ព័ន្ធធនាគារ ។ សម្ព័ន្ធធនាគារត្រួតពិនិត្យអង្គភាពនៅពេលដែល មានសិទ្ធិ មានប្រាក់ចំណូលមិនទៀងទាត់ ពីការរួមបញ្ចូលអាជីវកម្ម និងមានលទ្ធភាពដែលធ្វើឲ្យប៉ះពាល់ដល់ចំណូលរបស់អង្គភាព ។ របាយការណ៍ហិរញ្ញវត្ថុរបស់បុត្រសម្ព័ន្ធត្រូវរួមបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ចាប់តាំងពីថ្ងៃនៃការរួមបញ្ចូលការគ្រប់គ្រងរហូតដល់ថ្ងៃលក់អាជីវកម្ម ។

*(iii) ប្រតិបត្តិការលុបចោលនៅក្នុងការរួមបញ្ចូលអាជីវកម្ម*

ប្រតិបត្តិការ និងសមតុល្យក្នុងអន្តរសម្ព័ន្ធធនាគារ និងលទ្ធផលនៃប្រាក់ចំណេញ និងចំណាយមិនជាក់លាក់ត្រូវបានលុបចោលនៅពេលរៀបចំរបាយកាណ៍ហិរញ្ញវត្ថុរួម។ ការខាតបង់ដែលមិនទាន់បានទទួលស្គាល់ ដោយសារតែប្រតិបត្តិការក្នុងអន្តរសម្ព័ន្ធធនាគារ ត្រូវបានលុបចោលលើកលែងតែវាមិនអាចប្រមូលមកវិញបាន។

### (ខ) ឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ រួមមានសាច់ប្រាក់ និងសាច់ប្រាក់សមមូលឥណទាន គណនីត្រូវទទួលផ្សេងៗ ប្រាក់បញ្ញើ និងបំណុលផ្សេងៗ ។ គោលនយោបាយ គណនេយ្យលើការទទួលស្គាល់ និងការវាយតម្លៃនូវសមាសធាតុទាំងនេះ ត្រូវបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែកពីគ្នា ។

### (គ) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ និងសមតុល្យធនាគារ ប្រាក់បញ្ញើ ពុំមានកំហិតនៅធនាគារជាតិនៃកម្ពុជា ប្រាក់បញ្ញើចរន្តនៅស្ថាប័នហិរញ្ញវត្ថុដទៃទៀត និងការវិនិយោគរយៈពេលខ្លីដែលមានកាលវសាន្តនៅពេលតម្កល់ដំបូងមានរយៈពេល 3 ខែ ឬតិចជាង និង ដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ ។

### (ឃ) ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានាត្រូវបានកត់ត្រាតាមតម្លៃដើម ដកឱនភាពតម្លៃសម្រាប់ចំនួនណាដែលមិនប្រមូលវិញបាន។

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

#### (ង) ឥណទាន និងបុរេប្រទាន

រាល់ឥណទាន និងបុរេប្រទានផ្តល់ឲ្យអតិថិជន ត្រូវបានកត់ត្រានៅក្នុងតារាងតុល្យការតាមប្រាក់ដើមដកចំនួនទាំងឡាយណាដែលបានលុបចោល និងសំវិធានធនលើឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ ។
ឥណទាន ត្រូវបានលុបចោលនៅពេលដែលលទ្ធភាពនៃការប្រមូលបានមកវិញមិនមានភាពប្រាកដប្រជា ។ ការប្រមូលបានមកវិញនូវឥណទាន និងបុរេប្រទានដែលបានលុបចោល និងការបញ្ចូលមកវិញនូវសំវិធាន ធនពីមុន ត្រូវបានបង្ហាញជាចំណូលក្នុងរបាយការណ៍លទ្ធផល ។

#### (ច) សំវិធានធនលើឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ

អនុលោមតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា រាល់ឥណទាន និងបុរេប្រទាន ត្រូវបាន ចាត់ចំណាត់ថ្នាក់យោងទៅតាមសមត្ថភាពនៃការទូទាត់សងរបស់ដៃគូពាណិជ្ជកម្ម ។ សមត្ថភាពនៃការទូទាត់សងនេះ ត្រូវបានវាយតម្លៃដោយផ្អែកទៅតាមបទពិសោធន៍នៃការទូទាត់សងពីមុន លក្ខខណ្ឌហិរញ្ញវត្ថុរបស់កូនបំណុល អាជីវកម្ម និងលំហូរទឹកប្រាក់នាពេលអនាគត លទ្ធភាព និងការស្ម័គ្រចិត្តសងរបស់កូនបំណុលបរិយាកាសហិរញ្ញវត្ថុ និងគុណភាពនៃឯកសារដែលប្រមូលបាន ។

បន្ថែមលើគុណភាពនៃព័ត៌មានខាងលើ ចំនួនថ្ងៃហួសកាលកំណត់សងត្រូវបានយកមកគិត ដូចខាង ក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃហួសកាលកំណត់សង | | សំវិធានធន |
|---|---|---|---|
| ឥណទានធម្មតា/ស្តង់ដារ | <30 ថ្ងៃ | 1% | សំវិធានធនទូទៅ |
| ឥណទានឃ្លាំមើល | ≥ 30 ថ្ងៃ – 89ថ្ងៃ | 3% | សំវិធានធនជាក់លាក់ |
| ឥណទានក្រោមស្តង់ដារ | ≥ 90 ថ្ងៃ – 179 ថ្ងៃ | 20% | សំវិធានធនជាក់លាក់ |
| ឥណទានជាប់សង្ស័យ | ≥ 180ថ្ងៃ– 359ថ្ងៃ | 50% | សំវិធានធនជាក់លាក់ |
| ឥណទានបាត់បង់ | 360ថ្ងៃ ឬច្រើនជាង | 100% | សំវិធានធនជាក់លាក់ |

សំវិធានធនលើឥណទាន និងបុរេប្រទានជាប់សង្ស័យអប្បបរមា ត្រូវបានកំណត់ដោយផ្អែកទៅតាម ចំណាត់ថ្នាក់ដែលបានចាត់ថ្នាក់ ។ នៅពេលមានព័ត៌មានដែលអាចទុកចិត្តបានថា ការបាត់បង់នឹង កើតមានឡើងច្រើនជាងតម្រូវការអប្បបរមានោះ សំវិធានធនបន្ថែមនឹងត្រូវបានធ្វើឡើង ។

សំវិធានធនខាងលើ ត្រូវបានធ្វើឡើងដោយមិនគិតពីតម្លៃនៃទ្រព្យបញ្ចាំទេ លើកលែងតែទ្រព្យបញ្ចាំ នោះ ជាសាច់ប្រាក់ដែលបានតម្កល់នៅធនាគារ ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ច) សំវិធានធនលើឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ (ត)

ការប្រមូលមកវិញនូវឥណទាន និងបុរេប្រទានដែលបានលុបបំបាត់ចោល និងការបញ្ចូលមកវិញនូវសំវិធានធនពីមុន ត្រូវបានបង្ហាញជាចំណូលផ្សេងៗក្នុងរបាយការណ៍លទ្ធផល ។

ឥណទានមិនអាចទារបាន ឬចំណែកនៃឥណទានដែលបានចាត់ថ្នាក់ជាឥណទានអាក្រក់នឹងត្រូវលុប បំបាត់បន្ទាប់ពីមានការគិតគូរទៅលើតម្លៃលក់បាននៃទ្រព្យបញ្ចាំ ហើយប្រសិនបើនៅពេលដែលអ្នក គ្រប់គ្រងវិនិច្ឆ័យឃើញថា ពុំមានសង្ឃឹមនឹងទារបាននូវឥណទានទាំងនោះមកវិញទេ ។

### (ឆ) ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាទៅតាមតម្លៃដើម។ការប៉ាន់ប្រមាណមួយត្រូវបានធ្វើឡើងសម្រាប់ការសង្ស័យដែលមានមូលដ្ឋានលើការពិនិត្យឡើងវិញនៃចំនួនទឹកប្រាក់នៅកាលបរិច្ឆេទនៃការធ្វើរបាយការណ៍នេះ។

### (ជ) ប្រាក់បញ្ញើតម្កល់តាមច្បាប់

ប្រាក់បញ្ញើតម្កល់តាមច្បាប់ សម្រាប់សកម្មភាពប្រតិបត្តិការធនាគារ ត្រូវបានរក្សាទុកនៅធនាគារជាតិ នៃកម្ពុជាស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបាន កំណត់ជាភាគរយនៃដើមទុនអប្បបរមារបស់ធនាគារ និងប្រាក់បញ្ញើរបស់អតិថិជនដែលតម្រូវដោយ ធនាគារជាតិនៃកម្ពុជា ។ ប្រាក់បញ្ញើតម្កល់តាមច្បាប់ ត្រូវបានកត់ត្រាទៅតាមតម្លៃដើម ។

### (ឈ) ភតិសន្យាប្រតិបត្តិការ

ភតិសន្យាត្រូវបានចាត់ទុកជាភតិសន្យាប្រតិបត្តិការ នៅពេលម្ចាស់ដីរក្សាទុកនូវការផ្ទេរសិទ្ធិនៃទ្រព្យសកម្មក្រោយភតិសន្យា ។ ថ្លៃឈ្នួលដែលបានបង់លើភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលតាមវិធីសាស្រ្តរំលស់ថេរទៅតាមថេរវេលានៃភតិសន្យា។

ភតិសន្យាលើ ដី និងអគារ ត្រូវបានចាត់ថ្នាក់ជាភតិសន្យាហិរញ្ញប្បទាន នៅពេលដែលហានិភ័យ និងផលប្រយោជន៍ត្រូវបានផ្តល់ដល់អ្នកជួល នៅក្នុងអំឡុងពេលជួលនៃទ្រព្យសកម្មទោះបីជាគ្មានការផ្ទេរប្តូរនៅចុងការិយបច្ឆេទនៃភតិសន្យាក៏ដោយ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ញ) ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីរួមមាន កុំព្យូទ័រសូហ្វវែរ ដែលរាប់បញ្ចូលថ្លៃដើមនៅពេលទិញ និងថ្លៃដើមក្នុងការស្ថាបនាដែលមិនបានដាក់បញ្ចូលជាមួយនិងផ្នែកប្រតិបត្តិការរបស់កុំព្យូទ័រ ហើយត្រូវបានកំណត់តម្លៃ ដោយយកថ្លៃដើមដករំលស់បង្គរ និងឱនភាពនៃតម្លៃប្រសិនបើមាន ។ រំលស់លើទ្រព្យសកម្មអរូបីត្រូវបានទទួលស្គាល់ជាចំណាយក្នុងរបាយការណ៍លទ្ធផលដោយផ្អែកលើមូលដ្ឋានរំលស់ថេរតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសកម្មនីមួយៗតាមអត្រា ដូចខាងក្រោម៖

| | |
|---|---|
| កម្មវិធីកុំព្យូទ័រ (Moneta) | 20% |
| កម្មវិធីកុំព្យូទ័រ (Swift) | 50% |

### (ដ) ទ្រព្យ និងបរិក្ខារ

(i) ផ្នែកនៃទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកត់ត្រាតាមតម្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាព តម្លៃបង្គរប្រសិនបើមាន។ នៅពេលដែលធាតុនៃទ្រព្យសម្បត្តិ និងបរិក្ខារមានអាយុកាលប្រើប្រាស់ខុសៗ គ្នា ធាតុទាំងនោះ ត្រូវបានចាត់ទុកជាផ្នែកផ្សេងគ្នារបស់ទ្រព្យសម្បត្តិ និងបរិក្ខារ។

(ii) រំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានទទួលស្គាល់ជាចំណាយទៅក្នុងរបាយការណ៍លទ្ធផល ដោយផ្អែកលើមូលដ្ឋានរំលស់ថេរដែលមានអត្រារំលស់ប្រចាំឆ្នាំដូចខាងក្រោម៖

| | |
|---|---|
| ការកែលម្អដីនិងអគារ | 2% |
| ការជួសជុលកែលម្អ | 20% |
| គ្រឿងសង្ហារឹម និងសម្ភារការិយាល័យ | 25% |
| បរិក្ខារព័ត៌មានវិទ្យា | 50% |
| យានយន្ត | 25% |

(iii) ការងារកំពុងដំណើរការ មិនត្រូវបានរំលស់ទេ រហូតទាល់តែទ្រព្យទាំងនេះបានបញ្ចប់ ហើយបាន ដាក់ឲ្យប្រើប្រាស់នៅក្នុងប្រតិបត្តិការអាជីវកម្ម ។

(iv) ការចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យ និងបរិក្ខារដែលបានទទួលស្គាល់រួចមក ហើយត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍ សេដ្ឋកិច្ចនាពេលអនាគតដល់សម្ព័ន្ធធនាគារ និងធនាគារ លើសពីស្តង់ដារដើម ។ រាល់ការចំណាយ បន្ទាប់ផ្សេងទៀតត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង ។

3. **គោលនយោបាយគណនេយ្យសំខាន់ៗ** (ត)

**(ដ) ទ្រព្យ និងបរិក្ខារ (ត)**

(v) ចំណេញ ឬខាតពីការឈប់ប្រើ ឬការលក់ចេញផ្នែកនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានកំណត់ ដោយភាពខុសគ្នា រវាងសាច់ប្រាក់ទទួលបានពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបាន ទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលនាថ្ងៃឈប់ប្រើ ឬលក់ចេញ ។

(vi) ទ្រព្យ និងបរិក្ខារដែលបានដករំលស់អស់ហើយត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូត ដល់ថ្ងៃដែលទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានលក់ចេញ ឬលុបបំបាត់ចោល ។

**(ថ) ឱនភាពនៃតម្លៃទ្រព្យសកម្ម**

*(i) ទ្រព្យសកម្មហិរញ្ញវត្ថុ*

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាយតម្លៃនាការិយបរិច្ឆេទរាយការណ៍ដើម្បីកំណត់ថាតើមានភស្តុតាង ណាមួយដែលបង្ហាញថា ទ្រព្យសកម្មហិរញ្ញវត្ថុទាំងនោះមានឱនភាពនៃតម្លៃ ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវចាត់ទុកថាមានឱនភាពនៃតម្លៃ ប្រសិនបើមានហេតុការណ៍មួយ ឬច្រើនជះឥទ្ធិពលអវិជ្ជមានទៅលើលំហូរទឹកប្រាក់ប៉ាន់ស្មាននាពេលអនាគតដល់ទ្រព្យសកម្មនោះ ។ ករណីនេះមិនត្រូវបានប្រើប្រាស់សម្រាប់ឥណទាន និងបុរេប្រទាន ដោយវាត្រូវបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែក នៅក្នុងកំណត់សំគាល់ 3 (ង) និង 3 (ច) ។

ការខាតបង់លើឱនភាពនៃតម្លៃលើទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានគណនាដោយផ្អែកលើភាពខុសគ្នា រវាងតម្លៃនាពេលអនាគត និងតម្លៃបច្ចុប្បន្ន នៃលំហូរទឹកប្រាក់រំពឹងនឹងទទួលបាននាពេលអនាគត ដោយធ្វើការបញ្ចុះតម្លៃតាមអត្រាការប្រាក់ប្រសិទ្ធភាព ។

រាល់ទ្រព្យសកម្មហិរញ្ញវត្ថុសំខាន់ៗ ត្រូវបានត្រួតពិនិត្យទៅលើឱនភាពនៃតម្លៃតាមទ្រព្យសកម្មនីមួយៗ ។ ទ្រព្យសកម្មហិរញ្ញវត្ថុនៅសល់ ត្រូវបានវាយតម្លៃជារួមសម្រាប់ទ្រព្យសកម្មដែលមានហានិភ័យឥណទាន
ស្រដៀងគ្នា ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។
ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវដកចេញប្រសិនបើមានព្រឹត្តិការណ៍កើតឡើងក្រោយពីការទទួលស្គាល់ការខាតបង់លើឱនភាពនៃតម្លៃតម្រូវឲ្យដកចេញ ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ថ) ឱនភាពនៃតម្លៃទ្រព្យសកម្ម(ត)

*(ii) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ .*

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ត្រូវបានត្រួតពិនិត្យនៅរាល់ការិយបរិច្ឆេទ រាយការណ៍ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថា ទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃឬទេ ។ប្រសិនបើមានសញ្ញាណនោះកើតឡើង ការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលបានវិញរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង ។

តម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាង ប៉ាន់ប្រមាណតម្លៃប្រើប្រាស់ និងតម្លៃសមស្របដកចំណាយដើម្បីលក់ចេញ ។ ក្នុងការវាយតម្លៃ លើតម្លៃប្រើប្រាស់សាច់ប្រាក់រំពឹងថានឹងទទួលបាននាពេលអនាគត ត្រូវបានបញ្ចុះទៅតម្លៃបច្ចុប្បន្ន ដោយប្រើប្រាស់អត្រាការប្រាក់មុនបង់ពន្ធដែលឆ្លុះបញ្ចាំងពី ការប៉ាន់ប្រមាណនៃតម្លៃពេលវេលាក្នុង លក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និង ហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ ។ សម្រាប់គោល បំណងនៃការត្រួតពិនិត្យលើឱនភាពនៃតម្លៃទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុម ដែលអាច បង្កើតសាច់ប្រាក់ បានតូចបំផុតពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់ នៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀត ហៅកាត់ថា (“ឯកតាបង្កើតសាច់ប្រាក់”)។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មមួយ ឬ ឯកតាបង្កើតសាច់ប្រាក់មានចំនួនលើសពីតម្លៃ ដែលអាចប្រមូលមកបានវិញ ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

ប្រសិនបើការខាតបង់ លើឱនភាពនៃតម្លៃមានការថយចុះនៅពេលបន្ទាប់ តម្លៃយោងរបស់ទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្មដែលពាក់ព័ន្ធ នឹងត្រូវបង្កើនទៅតម្លៃដែលអាចប្រមូលបានវិញ ដែលបានប៉ាន់ស្មាន ជាថ្មី ប៉ុន្តែមិនត្រូវឲ្យលើសពីកម្រិតតម្លៃយោងនៃទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្មដែលពាក់ព័ន្ធ ដែលបាន កំណត់កាលពីការិយបរិច្ឆេទមុន ថាគ្មានការខាតបង់លើឱនភាពនៃតម្លៃទ្រព្យសកម្មនោះទេ ។ ការដាក់បញ្ចូលមកវិញនូវការខាតបង់លើឱនភាពនៃតម្លៃនេះគឺត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

### (ឌ) សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងតារាងតុល្យការ នៅពេលដែលសម្ព័ន្ធធនាគារ និងធនាគារ មាននូវកាតព្វកិច្ច តាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយមានលទ្ធភាពដែលតម្រូវឲ្យមាន លំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ចនោះ ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឌ) សំវិធានធន (ត)

ប្រសិនបើផលប៉ះពាល់មានលក្ខណៈជាសារវន្ត សំវិធានធន ត្រូវបានកំណត់ ដោយអប្បហារលំហូរទឹកប្រាក់ដែលរំពឹងទុកនាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណនៃតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់នៃបំណុល ។

### (ឍ) ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារនានា

ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារនានា ត្រូវបានកត់ត្រាតាមតម្លៃដើម ។

### (ណ) ការទទួលស្គាល់ប្រាក់ចំណូល

ចំណូលពីការប្រាក់ ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានបង្គរ ។

ចំណូលពីការប្រាក់លើឥណទានវិបារូបន៍ ឥណទានមានកាលកំណត់ និងឥណទានផ្សេងៗ ត្រូវបាន ទទួលស្គាល់ដោយយោងទៅតាមពេលវេលាដែលគិតប្រចាំខែ ឬប្រចាំថ្ងៃ ។ នៅពេលដែលគណនី ត្រូវបានចាត់ថ្នាក់ជាឥណទានមិនដំណើរការ ការប្រាក់នឹងត្រូវព្យួរទុកលុះត្រាតែវាទទួលបានជាសាច់ប្រាក់សុទ្ធ ។ គណនីអតិថិជនដែលចាត់ទុកជាគណនីមិនដំណើរការគឺនៅពេលដែលខកខាន មិនបានសងបំណុលលើសពី 3 ខែ ។

ចំណូលពីសកម្មភាពផ្សេងៗរបស់ធនាគារ ត្រូវបានបង្គរដោយប្រើប្រាស់មូលដ្ឋានដូចខាងក្រោម៖

- កម្រៃលើការចាត់ចែងផ្តល់ឥណទាន និងកម្រៃជើងសារលើសេវាកម្ម និងឥណទានដែលបានផ្តល់ទៅឲ្យអតិថិជន ត្រូវបានទទួលស្គាល់នៅពេលប្រតិបត្តិការកើតឡើង ។
- កម្រៃលើកិច្ចសន្យា និងកម្រៃការធានាលើសេវាកម្មផ្សេងៗ និងឧបករណ៍ហិរញ្ញវត្ថុនានាដែលផ្តល់ ឲ្យអតិថិជនត្រូវបានទទួលស្គាល់ជាចំណូលនៅក្នុងការិយបរិច្ឆេទដែលសេវាកម្ម និងឧបករណ៍ ហិរញ្ញវត្ថុទាំងនោះត្រូវបានផ្តល់ឲ្យ ។
- កម្រៃសេវាកម្ម និងកម្រៃរត់ការ ត្រូវបានទទួលស្គាល់នៅពេលដែលសេវាកម្មត្រូវបានបំពេញ និង
- ចំណូលពីការជួលទ្រព្យស្ថិតក្រោមប្រតិបត្តិការភតិសន្យា ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលនៅលើមូលដ្ឋានរំលស់ថេរនៃរយៈពេលនៃភតិសន្យានេះ ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ប) ចំណាយលើការប្រាក់

ចំណាយលើការប្រាក់ទៅលើប្រាក់បញ្ញើ ត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរប្រចាំថ្ងៃ ។

### (ផ) ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញ ឬខាតក្នុងការិយបរិច្ឆេទរួមមានពន្ធលើប្រាក់ចំណេញ ប្រចាំឆ្នាំ និងពន្ធពន្យារ ។ ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល លើកលែងតែក្នុងករណីដែលវាទាក់ទងទៅនឹងសមាសធាតុ ដែលត្រូវទទួលស្គាល់ជាផ្នែកមួយនៃមូលធន ក្នុងករណីនេះវាក៏ត្រូវបានកំណត់បង្ហាញជាផ្នែកមួយនៃមូលធនផងដែរ ។

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងទុកថា ត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធក្នុង ការិយបរិច្ឆេទ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នាកាលបរិច្ឆេទរាយការណ៍ ជាមួយនឹងនិយ័តភាពណាមួយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ ។

ពន្ធពន្យារ ត្រូវបានកត់ត្រាតាមវិធីសាស្ត្រតារាងតុល្យការទៅលើភាពលំអៀងជាបណ្តោះអាសន្នរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោង ប្រើសម្រាប់ការគិតពន្ធ ។ តម្លៃនៃប្រាក់ពន្ធពន្យារដែលបានកំណត់នោះគឺផ្អែកលើលក្ខណ:នៃការ
ជឿជាក់នឹងទទួលបាន ឬការទូទាត់ដែលនឹងកើតឡើងរវាងតម្លៃសុទ្ធនៃទ្រព្យសកម្ម និងបំណុល ដោយប្រើអត្រាពន្ធកំណត់នៅនាកាលបរិច្ឆេទរាយការណ៍ ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់តែក្នុងករណីអាចនឹងកើតមានឡើងទៅលើប្រាក់ចំណេញ ជាប់ពន្ធនាពេលអនាគត ដែលអាចប្រើប្រាស់ជាមួយនឹងទ្រព្យសកម្ម ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានកាត់បន្ថយក្នុងករណីដែលវាមិនអាចកើតឡើងនូវអត្ថប្រយោជន៍នៃពន្ធដែលពាក់ព័ន្ធ ដែលអាចនឹងប្រើប្រាស់បាន ។

### (ព) សម្ព័ន្ធញាតិ

ភាគីដែលត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិ ប្រសិនបើ សម្ព័ន្ធធនាគារ និងធនាគារ មានលទ្ធភាពគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោល ឬមានឥទ្ធិពលខ្លាំងទៅលើភាគីមួយទៀត ក្នុងការធ្វើសេចក្តីសម្រេចហិរញ្ញវត្ថុ និងប្រតិបត្តិការ ឬក្រុមហ៊ុនហើយសម្ព័ន្ធធនាគារ និងធនាគារ នោះស្ថិតនៅក្រោមការគ្រប់គ្រងរួមមួយ ឬក៏មានឥទ្ធិពលខ្លាំង ។ សម្ព័ន្ធញាតិអាចជារូបវ័ន្តបុគ្គល ឬនីតិបុគ្គល ហើយក៏រួមបញ្ចូលនូវសមាជិកគ្រួសារជិតស្និទ្ធ ជាមួយនឹងរូបវន្តបុគ្គលជាសម្ព័ន្ធញាតិផងដែរ ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ព) សម្ព័ន្ធញាតិ (ត)

តាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សម្ព័ន្ធញាតិរួមបញ្ចូលផងដែរនូវរូបវន្តបុគ្គលដែលមាន ភាគហ៊ុនយ៉ាងតិចចំនួន 10% នៃដើមទុនរបស់ធនាគារ ឬនៃសិទ្ធិបោះឆ្នោត ទោះជាកាន់កាប់ដោយ ផ្ទាល់ក្តី ឬដោយប្រយោលក្តី ឬរូបវន្តបុគ្គលណាដែលរួមចំណែកក្នុងផ្នែករដ្ឋបាល ការដឹកនាំការគ្រប់គ្រង ឬការរៀបចំ និងការអនុវត្តនូវការត្រួតពិនិត្យផ្ទៃក្នុងរបស់សម្ព័ន្ធធនាគារ និងធនាគារ ។

## 4. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាដុល្លារអាមេរិក ។ ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល ត្រូវបានធ្វើឡើងដើម្បីអនុវត្តទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាផ្លូវការប្រកាសដោយធនាគារជាតិនៃកម្ពុជា នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 ដែល 1 ដុល្លារអាមេរិក ស្មើនឹង 4,037 រៀល(នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ2015៖1 ដុល្លារអាមេរិក ស្មើនឹង 4,050 រៀល)។ តួលេខជាប្រាក់រៀលនេះ គឺសម្រាប់ជាការបង្ហាញតែប៉ុណ្ណោះ ហើយមិនត្រូវបានយកមកបកស្រាយថាតួលេខប្រាក់ដុល្លារអាមេរិកនេះ ត្រូវបានប្តូរទៅជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀលនាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ ។

# ធនាគារភ្នំពេញពាណិជ្ជ

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

5. **សាច់ប្រាក់ និងសមតុល្យធនាគារ**

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | 2016 | | 2015 | | 2016 | | 2015 | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក (កំណត់សំគាល់ 4) | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក (កំណត់សំគាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នៅក្នុងព្រះរាជាណាចក្រកម្ពុជា: | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ 10,208,335 | 41,211,048 | 10,022,110 | 40,589,546 | 10,208,335 | 41,211,048 | 10,022,110 | 40,589,546 | |
| សមតុល្យក្នុងធនាគារ | | | | | | | | |
| ធនាគារជាតិនៃកម្ពុជា | 11,127,910 | 44,923,373 | 36,750,951 | 148,841,351 | 11,127,910 | 44,923,373 | 36,750,951 | 148,841,351 |
| ធនាគារនិងស្ថាប័ន | | | | | | | | |
| ហិរញ្ញវត្ថុផ្សេងៗ | 2,463,826 | 9,946,466 | 1,577,703 | 6,389,697 | 2,463,826 | 9,946,466 | 1,577,703 | 6,389,697 |
| | 23,800,071 | 96,080,887 | 48,350,764 | 195,820,594 | 23,800,071 | 96,080,887 | 48,350,764 | 195,820,594 |
| នៅក្រៅព្រះរាជាណាចក្រកម្ពុជា: | | | | | | | | |
| សមតុល្យនៅធនាគារ | 5,724,446 | 23,109,588 | 14,136,272 | 57,251,902 | 5,724,446 | 23,109,588 | 14,136,272 | 57,251,902 |
| | 29,524,517 | 119,190,475 | 62,487,036 | 253,072,496 | 29,524,517 | 119,190,475 | 62,487,036 | 253,072,496 |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

### 5. សាច់ប្រាក់ និងសមតុល្យធនាគារ(ត)

សាច់ប្រាក់ និងសមតុល្យធនាគារខាងលើ ត្រូវបានធ្វើការវិភាគដូចខាងក្រោម៖

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | 2016 | | 2015 | | 2016 | | 2015 | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) |
| (ក) តាមរូបិយប័ណ្ណ: | | | | | | | | |
| ប្រាក់ដុល្លារអាមេរិក | 29,440,252 | 118,850,297 | 62,342,026 | 252,485,205 | 29,440,252 | 118,850,297 | 62,342,026 | 252,485,205 |
| ប្រាក់រៀលខ្មែរ | 78,643 | 317,482 | 52,850 | 214,043 | 78,643 | 317,482 | 52,850 | 214,043 |
| រូបិយប័ណ្ណផ្សេងៗ | 5,622 | 22,696 | 92,160 | 373,248 | 5,622 | 22,696 | 92,160 | 373,248 |
| | 29,524,517 | 119,190,475 | 62,487,036 | 253,072,496 | 29,524,517 | 119,190,475 | 62,487,036 | 253,072,496 |

| | សម្ព័ន្ធធនាគារ | | ធនាគារ | |
|---|---|---|---|---|
| | 2016 | 2015 | 2016 | 2015 |
| (ខ) តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ): | | | | |
| ធនាគារនៅក្នុងស្រុក | 0.25% - 2.50% | 0.25% - 3.00% | 0.25% - 3.00% | 0.25% - 3.00% |
| ធនាគារនៅបរទេស | 0.01% - 0.02% | 0.01% - 0.02% | 0.01% - 0.02% | 0.01% - 0.02% |

# ធនាគារភ្នំពេញពាណិជ្ជ

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

### 6. ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនិងស្ថាប័នហិរញ្ញវត្ថុនានា

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | 2016 | | 2015 | | 2016 | | 2015 | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) |
| ធនាគារជាតិនៃកម្ពុជា | 2,400,000 | 9,688,800 | 1,400,000 | 5,670,000 | 2,400,000 | 9,688,800 | 1,400,000 | 5,670,000 |
| ធនាគារក្នុងស្រុក | 62,100,000 | 250,697,700 | 58,100,000 | 235,305,000 | 62,100,000 | 250,697,700 | 58,100,000 | 235,305,000 |
| ស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | 12,415,000 | 50,119,355 | 8,638,750 | 34,986,938 | 12,415,000 | 50,119,355 | 8,638,750 | 34,986,938 |
| | 76,915,000 | 310,505,855 | 68,138,750 | 275,961,938 | 76,915,000 | 310,505,855 | 68,138,750 | 275,961,938 |

## 6. ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនិងស្ថាប័នហិរញ្ញវត្ថុនានា(ត)

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារ និងស្ថាប័នហិរញ្ញវត្ថុនានាត្រូវបានធ្វើការវិភាគដូចខាងក្រោម៖

(ក) តាមកាលវសាន្ត

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | 2016 | | 2015 | | 2016 | | 2015 | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) |
| រយៈពេល 3 ខែ | 10,400,000 | 41,984,800 | 2,400,000 | 9,720,000 | 10,400,000 | 41,984,800 | 2,400,000 | 9,720,000 |
| 4 ទៅ 6 ខែ | 9,500,000 | 38,351,500 | 5,250,000 | 21,262,500 | 9,500,000 | 38,351,500 | 5,250,000 | 21,262,500 |
| 7 ទៅ 12 ខែ | 54,015,000 | 218,058,555 | 57,488,750 | 232,829,438 | 54,015,000 | 218,058,555 | 57,488,750 | 232,829,438 |
| លើសពី 12 ខែ | 3,000,000 | 12,111,000 | 3,000,000 | 12,150,000 | 3,000,000 | 12,111,000 | 3,000,000 | 12,150,000 |
| សរុប | 76,915,000 | 310,505,855 | 68,138,750 | 275,961,938 | 76,915,000 | 310,505,855 | 68,138,750 | 275,961,938 |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

### 6. ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនិងស្ថាប័នហិរញ្ញវត្ថុនានា(ត)

(ខ) រូបិយប័ណ្ណ

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | 2016 | | 2015 | | 2016 | | 2015 | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) |
| ដុល្លារអាមេរិក | 76,915,000 | 310,505,855 | 68,138,750 | 275,961,938 | 76,915,000 | 310,505,855 | 68,138,750 | 275,961,938 |

(គ) តាមអត្រាការប្រាក់ (ប្រចាំឆ្នាំ):

| | សម្ព័ន្ធធនាគារ | | ធនាគារ | |
|---|---|---|---|---|
| | 2016 | 2015 | 2016 | 2015 |
| ធនាគារជាតិនៃកម្ពុជា | 0.2% - 0.47% | 0.15% | 0.2% - 0.47% | 0.15% |
| ធនាគារក្នុងស្រុក | 2.5% - 5.5% | 3.2% - 5.5% | 2.5% - 5.5% | 3.2% - 5.5% |
| ស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | 5.7% - 6.9% | 5.7% - 6.9% | 5.7% - 6.9% | 5.7% - 6.9% |

# ធនាគារភ្នំពេញពាណិជ្ជ

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

### 7. ឥណទាន និងបុរេប្រទាន - សុទ្ធ

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | 2016 | | 2015 | | 2016 | | 2015 | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) |
| ឥណទានវិបារូបន៍ | 15,319,818 | 61,846,105 | 11,915,459 | 48,257,609 | 15,319,818 | 61,846,105 | 11,915,459 | 48,257,609 |
| ឥណទានមានកាលកំណត់ | 288,419,538 | 1,164,349,675 | 212,383,494 | 860,153,151 | 288,929,538 | 1,166,408,545 | 212,383,494 | 860,153,151 |
| ឥណទានគេហដ្ឋាន | 7,282,357 | 29,398,875 | 3,213,775 | 13,015,789 | 7,282,357 | 29,398,875 | 3,213,775 | 13,015,789 |
| ឥណទានយានយន្ត | 1,006,960 | 4,065,098 | 901,975 | 3,652,998 | 1,006,960 | 4,065,098 | 901,975 | 3,652,998 |
| ឥណទាន និងបុរេប្រទាន ដុល | 312,028,673 | 1,259,659,753 | 228,414,703 | 925,079,547 | 312,538,673 | 1,261,718,623 | 228,414,703 | 925,079,547 |
| សំវិធានធនលើឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ | | | | | | | | |
| ទូទៅ | (3,097,300) | (12,503,800) | (2,283,793) | (9,249,362) | (3,102,400) | (12,524,389) | (2,283,793) | (9,249,362) |
| ជាក់លាក់ | (438,619) | (1,770,705) | (8,229) | (33,327) | (438,619) | (1,770,705) | (8,229) | (33,327) |
| | (3,535,919) | (14,274,505) | (2,292,022) | (9,282,689) | (3,541,019) | (14,295,094) | (2,292,022) | (9,282,689) |
| **ឥណទាន និងបុរេប្រទាន-សុទ្ធ** | 308,492,754 | 1,245,385,248 | 226,122,681 | 915,796,858 | 308,997,654 | 1,247,423,529 | 226,122,681 | 915,796,858 |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

### 7. ឥណទាន និងបុរេប្រទាន - សុទ្ធ (ត)

ការវិភាគបន្ថែមទៅលើឥណទាន និងបុរេប្រទានមានដូចខាងក្រោម៖

(ក) បម្រែបម្រួលសំវិធានធនលើឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ មានដូចខាងក្រោម៖

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | 2016 | | 2015 | | 2016 | | 2015 | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 4) |
| នាថ្ងៃទី1 ខែមករា | 2,292,022 | 9,282,689 | 1,707,937 | 6,959,843 | 2,292,022 | 9,282,689 | 1,707,937 | 6,959,843 |
